# អង្គការជនពិការកម្ពុជា

# របាយការណ៍

# ស្តីពី

# ស្ថានភាពបច្ចុប្បន្ននៃការអប់រំកុមារពិការ










ភ្នំពេញ

ខែ មេសា ឆ្នាំ ២០១០

# អង្គការជនពិការកម្ពុជា

# របាយការណ៍
# ស្តីពី
# ស្ថានភាពបច្ចុប្បន្ននៃការអប់រំកុមារពិការ

អ្នករៀបចំអត្ថបទ: **កញ្ញា ហេង ចន្ធី** មន្ត្រីកម្មវិធីជាន់ខ្ពស់ អ.ព.ក
**លោក ខាំ ពិសិដ្ឋ** ប្រធានគ្រប់គ្រងកម្មវិធី អ.ព.ក
**កញ្ញា ខួន សុភកណិកា** អ្នកពិគ្រោះសិទ្ធិជនពិការ អេកអាយប៊ី

អ្នកកែសម្រួល: **អ្នកស្រី ម៉ារីយ៉ាន ស្ទូម៉ាសឺរ** ទីប្រឹក្សា អ.ព.ក
**លោក ម៉ាក ម៉ូរីសាន់** ទីប្រឹក្សាពិការភាព អេកអាយប៊ី

ឧបត្ថម្ភដោយ: HANDICAP INTERNATIONAL

ភ្នំពេញ
ខែ មេសា ឆ្នាំ ២០១០

របាយការណ៍នេះត្រូវបានបោះពុម្ពក្រោមជំនួយឧបត្ថម្ភរបស់អង្គការជនពិការអន្តរជាតិប្រទេសបែលហ្ស៊ិច ។ ចំពោះមាតិកានៃ របាយការណ៍នេះ អង្គការជនពិការកម្ពុជា សូមទទួលខុសត្រូវជាផ្លូវការ ដោយមិនមានការពាក់ព័ន្ធនឹងអង្គការជនពិការអន្តរជាតិប្រទេស បែលហ្ស៊ិចឡើយ ។

# សេចក្តីថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវ និង ការផលិតរបាយការណ៍ស្រាវជ្រាវ ស្តីពី ស្ថានភាពកុមារពិការ មុនការអនុវត្តគោលនយោបាយអប់រំកុមារពិការ នឹងមិនទទួលបានជោគជ័យ ប្រសិនបើមិនមានការគាំទ្រ និងកិច្ចសហការ ពីបុគ្គលជាច្រើន។ អង្គការជនពិការកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់:

ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្រ្តីក្រសួងអប់រំ យុវជន និងកីឡា និង ឯកឧត្តម **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ដែលផ្តល់ការអនុញ្ញាត និងសម្របសម្រួលដល់ការស្រាវជ្រាវនៅក្នុង ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តស្វាយរៀង និង ខេត្ត បន្ទាយមានជ័យ ។

បណ្ឌិត **ម៉ាយ៉ា កល្យាណពួរ** ទីប្រឹក្សាការអប់រំបញ្ចូលគ្នានៃក្រសួងអប់រំ យុវជន និងកីឡា និង លោក **ញ៉ាន សារឿន** ប្រធានការិយាល័យអប់រំពិសេស ដែលបានផ្តល់ពត៌មានទាក់ទងនឹងគោលនយោបាយ និង ការអនុវត្តន៍របស់ក្រសួងអប់រំ ។

សូមថ្លែងអំណរគុណផងដែរ ដល់អង្គការជនពិការអន្តរជាតិ ដែលផ្តល់ការគាំទ្រទាំងបច្ចេកទេស និងថវិកា។

អង្គការសកម្មភាពលើពិការភាព និងអភិវឌ្ឍន៍ អង្គការកម្ពុជាត្រាស្រ្ត ក្រុមប្រឹក្សាសកម្មភាពជនពិការ អង្គការហាការ អង្គការមនុស្សលោកថ្មី អង្គការភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល អង្គការគ្រួសារថ្មី សមាគមមាតាបិតានៃកុមារពិការខ្សោយបញ្ញា កម្មវិធីអភិវឌ្ឍមនុស្សថ្លង់ អង្គការទ្រទ្រង់ និងអភិវឌ្ឍន៍សុខភាពក្រីក្រ ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្ស និង គណៈកម្មាធិការបណ្តាញសិទ្ធិមនុស្សនិងពិការភាព ដែលជួយក្នុងការបង្កើតឧបករណ៍ប្រមូលទិន្នន័យ ការសរសេរ និង ការកែសម្រួលរបាយការណ៍នេះ ។

អង្គការជនពិការកម្ពុជា សំដែងនូវការកោតសរសើរ លោក **ជា សំណាង** ដែលបានផ្តល់វគ្គបណ្តុះបណ្តាល និង ណែនាំអំពីការស្រាវជ្រាវ និងវិធីសាស្រ្តប្រមូលពត៌មាន។ អរគុណផងដែរដល់ ក្រុមហ៊ុន ការស្រាវជ្រាវទីផ្សារ និងពិគ្រោះយោបល់ជំនួញ ដែលជួយអង្គការជនពិការក្នុងការបញ្ចូលទិន្នន័យ។

ការបង្កើតរបាយការណ៍នេះ នឹងអាចដំណើរការទៅបាន ដោយសារការជួយជ្រោមជ្រែងពីអង្គការតំណាងជនពិការមួយចំនួន ដែលបានសម្របសម្រួលក្នុងដំណើរការប្រមូលទិន្នន័យ។ យើងក៏សូមដឹងគុណជាពិសេសដល់ប្រធានមន្ទីរ និង ការិយាល័យអប់រំ យុវជន និងកីឡា ខេត្ត ស្រុក នាយកសាលា លោកគ្រូ អ្នកគ្រូ មាតាបិតារបស់កុមារពិការ និង កុមារពិការ ដែលបានចែករំលែកបទពិសោធន៍ និងចំណេះដឹងរបស់ខ្លួន។

ចុងបញ្ចប់ សូមថ្លែងអំណរគុណជាពិសេស ដល់ក្រុមការងាររបស់អង្គការជនពិការកម្ពុជា ដែលបានចូលរួមចំណែកទាំងកំលាំងកាយ កំលាំងចិត្ត និងពេលវេលា ក្នុងដំណើរការសរសេររបាយការណ៍ស្រាវជ្រាវនេះ តាំងពីចំនុចចាប់ផ្តើមរហូតដល់ទីបញ្ចប់។

# សេចក្តីសង្ខេប


គោលបំណងនៃការស្ទង់មតិ គឺដើម្បីចែករំលែកនូវទិដ្ឋភាពរួមនៃស្ថានភាពអប់រំកុមារពិការនាពេលបច្ចុប្បន្ន ក្នុងតំបន់ដែលបានជ្រើសរើស។ ការសិក្សានេះ ក៏ផ្តល់ពត៌មានជាមូលដ្ឋានដែលអាចឱ្យអង្គការជនពិការកម្ពុជា ត្រួតពិនិត្យ នូវវឌ្ឍនភាព ឆ្ពោះទៅរកការធ្វើឱ្យប្រសើឡើងដល់ការអប់រំកុមារពិការនៅក្នុងតំបន់ទាំងនេះ។

ពត៌មាននៃការសិក្សា បានទទួលតាមរយៈការសម្ភាសន៍ជាផ្លូវការជាលក្ខណៈបុគ្គល ដោយផ្អែកលើបញ្ជីសំនួរជាមួយមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នាយកសាលា លោកគ្រូ អ្នកគ្រូ កុមារពិការ និង/ឬ មាតាបិតាកុមារពិការ ។ ការសម្ភាសន៍មិនផ្លូវការតាមរយៈទូរស័ព្ទ ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ រួមមាន អង្គការសកម្មភាពលើពិការភាព និងអភិវឌ្ឍន៍ ក្រុមប្រឹក្សាសកម្មភាពជនពិការ ការិយាល័យអប់រំពិសេស ព្រមទាំងការពិភាក្សាជាមួយ អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើផ្នែកអប់រំកុមារពិការមួយចំនួនទៀត។ ឯកសារគោលនយោបាយផ្សេងៗគ្នា និងរបាយការណ៍ជាច្រើន ត្រូវបានពិគ្រោះយោលបល់ផងដែរ។

ការសម្ភាសន៍មិនផ្លូវការមួយចំនួន បានផ្តល់ពត៌មានបន្ថែម ស្តីពីគោលយោបាយអប់រំកុមារពិការ និងការបញ្ជាក់អះអាងពីសកម្មភាពសំខាន់ៗមួយចំនួននៅក្នុងផែនការមេ។ ការសម្ភាសន៍ទាំងអស់នោះ រួមមានបទសម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់នៃការិយាល័យអប់រំពិសេសនៃក្រសួងអប់រំ យុវជន និងកីឡា។

ការវិភាគទិន្នន័យ និងការសរសេររបាយការណ៍ ស្របគ្នាទៅនឹងការបោះពុម្ពផ្សាយផែនការមេសម្រាប់អប់រំកុមារពិការ។ ក្រុមស្រាវជ្រាវ បានសម្រេចរៀបចំជារបាយការណ៍ជារចនាសម្ព័ន្ធ ដើម្បីផ្តល់យោបល់ចំពោះសកម្មភាពមួយចំនួនដែលស្នើឡើងនៅក្នុងផែនការមេ។

របាយការណ៍នេះ ចាប់ផ្តើមជាមួយនឹងការពិនិត្យឡើងវិញនូវក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ជាតិ និងអន្តរជាតិបច្ចុប្បន្ន ដែលទាក់ទងការអប់រំកុមារពិការ។ គួរឱ្យកត់សំគាល់ មានភាពខុសគ្នាពាក់ព័ន្ធនឹងការកំណត់អត្ថន័យនៃ **"ពិការភាព"** នៅក្នុងអនុសញ្ញាអន្តរជាជាតិស្តីពីសិទ្ធិជនពិការ និងច្បាប់ជាតិស្តីពី កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ ទោះបីបានចុះហត្ថលេខាលើ អនុសញ្ញាសហប្រជាជាតិស្តីពី សិទ្ធិជនពិការ ដែលផ្តោតលើគំរូបែបសង្គម/សិទ្ធិជាមូលដ្ឋានក៏ដោយ អ្នកច្បាប់នៅក្នុងប្រទេសកម្ពុជា មិនទទួលស្គាល់ថា ការរារាំងពីឧបសគ្គផ្នែកសង្គម អាកប្បកិរិយា និងមជ្ឈដ្ឋានជុំវិញ លើការខូចខាត ឬបាត់មុខងារ/ផ្នែកណាមួយ នៃរូបរាងកាយ ជាលទ្ធផលនាំឱ្យមាន **"ពិការភាព"** ។

របាយការណ៍នេះ ពិពណ៌នាត្រួសៗពីផែនការមេសម្រាប់ការអប់រំ ដែលក្រសួងអប់រំ យុវជន និងកីឡា បានអនុម័ត សម្រាប់អនុវត្តន៍គោលនយោបាយអប់រំកុមារពិការ កាលពីខែកញ្ញា ឆ្នាំ២០០៩។ គោលបំណងនៃផែនការមេបានផ្តល់នូវមូលដ្ឋានសម្រាប់ការពិភាក្សាពីលទ្ធផលនៃការស្រាវជ្រាវៈ

<u>ការស្ទង់មតិពិនិត្យលើ៤ចំនុច :</u>

១- ចំណេះដឹងរបស់មន្ត្រីក្រសួង/មន្ទីរអប់រំ នាយកសាលា គ្រូបង្រៀន ពាក់ព័ន្ធគោលនយោបាយផ្សេងៗនៃការអប់រំកុមារពិការ ប្រភពពតិមានដែលពួកគេទទួលបាន ថាតើពួកគេបានទទួលវគ្គបំពាក់បំប៉នពីរបៀបអនុវត្តគោលនយោបាយទាំងនោះ ក្នុងរូបភាពដូចម្តេច និងថាតើមានធនធានគ្រប់គ្រាន់ដែរឬយ៉ាងណា។

២- ចំណេះដឹង នាយកសាលា និងគ្រូបង្រៀន ពីចំនួនកុមារពិការ នៅក្នុងតំបន់របស់ពួកគេ និងការយល់ដឹងពីសេចក្តីត្រូវការរបស់កុមារពិការ។

៣- គោលគំនិតយល់ឃើញរបស់មន្ត្រីក្រសួង/មន្ទីរអប់រំ នាយកសាលា និងគ្រូបង្រៀន ពីតម្រូវការរបស់កុមារពិការនៅសាលា។

៤- មធ្យោបាយដែលកុមារពិការអាចទៅសាលារៀនបាននៅក្នុងតំបន់របស់ពួកគេ និងទទួលបាននូវសម្ភារៈជំនួយសមស្រប។

ជាទូទៅ គេបានរកឃើញថា គម្លាតក្នុងការទទួលបានពតិមានមួយចំនួន ទំនងជាធំជាងអ្វីដែលមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានដឹង។ វាទំនងជាតម្រូវឱ្យមានការទំនាក់ទំនងដ៏មានប្រសិទ្ធិភាពជាងមុន រវាងក្រសួងអប់រំ យុវជន និងកីឡា និងសាលារៀន ព្រមទាំងការទទួលយកការពិតនូវបញ្ហាដែលកុមារពិការបានជួបប្រទះ។ ការស្រាវជ្រាវនេះ ក៏បានលាតត្រដាងពីកង្វះខាតធនធានសមស្របសម្រាប់ទាំងកុមារពិការ និងគ្រូបង្រៀន។ សាលារៀនមិនមានបំពាក់ឧបករណ៍សមស្រប ដើម្បីឆ្លើយតបតាមតម្រូវការរបស់កុមារពិការ ។

អង្គការជនពិការកម្ពុជា ទទួលស្គាល់ពីដែនកំណត់នៃការស្រាវជ្រាវនេះ។ បើទោះបីជាយ៉ាងណាក៏ដោយ វាទំនងជាបង្ហាញថា លទ្ធផលដែលបានរកឃើញ ចង្អុលបង្ហាញពីគំរូដ៏ទូលំទូលាយមួយ ដែលយើងសង្ឃឹមថា ផែនការមេអាចជួយដោះស្រាយ និងកែលម្អរបាន។

# មាតិកា

**សេចក្តីថ្លែងអំណរគុណ** ........................................ ១

**សេចក្តីសង្ខេប**........................................ ២

**មាតិកា** ........................................ ៤

**បញ្ជីអក្សរកាត់** ........................................ ៦

## ជំពូកទី ១

**សេចក្តីផ្តើម** ........................................ ៨

១.១-សារៈតានៃការស្ទង់មតិ ........................................ ៨

១.២-គោលបំណងនៃការស្ទង់មតិ........................................ ៩

## ជំពូកទី ២

**ទិដ្ឋភាពរួមនៃពិការភាព និងការអប់រំសំរាប់កុមារពិការនៅកម្ពុជា** ........................................ ១០

២.១ ស្ថានភាពទូទៅ នៃជនពិការ ........................................ ១០

២.១.១ និយមន័យជនពិការ ........................................ ១០

២.១.២ ទិន្នន័យជនពិការ ........................................ ១១

២.១.៣ ទិន្នន័យកុមារពិការក្នុងសាលារៀន ........................................ ១១

២.២ លិខិតគតិយុត្តទាក់ទងការអប់រំកុមារពិការ ........................................ ១២

២.២.១ លិខិតគតិយុត្តអន្តរជាតិ ........................................ ១២

២.២.២ លិខិតគតិយុត្តជាតិ និងការអនុវត្តគោលនយោបាយ ........................................ ១៣

## ជំពូកទី ៣

**វិធីសាស្រ្តស្ទង់មតិ** ........................................ ១៧

៣.១-ការជ្រើសសំណាក ........................................ ១៧

៣.២-ការប្រមូលទិន្នន័យ ........................................ ១៧

៣.៣- បញ្ហាប្រឈម និង ដែនកំណត់ ........................................ ១៨

## ជំពូកទី ៤

**លទ្ធផលនៃការស្ទង់មតិ** ........................................ ១៩

## ជំពូកទី ៥

**សេចក្តីសន្និដ្ឋាន** ........................................ ២៩

**ឯកសារយោង** ........................................ ៣១

**ឧបសម្ព័ន្ធ** ........................................ ៣៣

១-លិខិតអនុញ្ញាតផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា ........................................ ៣៣

២-បញ្ជីអ្នកផ្តល់ពតិមានសំខាន់ៗ ........................................ ៣៤

៣-កំរងសំនួរ ........................................ ៣៥

# បញ្ជីអក្សរកាត់

| | |
|---|---|
| **ADB** | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **ADD** | សកម្មភាពលើពិការភាព និងអភិវឌ្ឍន៍ |
| **CDHS** | ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា |
| **CDPO** | អង្គការជនពិការកម្ពុជា |
| **CSES** | ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចនៅកម្ពុជា |
| **CWD** | កុមារពិការ |
| **DAC** | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| **DCD** | នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា |
| **DPOs** | អង្គការតំណាងជនពិការ |
| **ECWD** | ការអប់រំសំរាប់កុមារពិការ |
| **EMIS** | ការិយាល័យប្រព័ន្ធពតិមានគ្រប់គ្រងអប់រំ |
| **FTI** | គម្រោងគំនិតផ្ដួចផ្ដើមឆាប់រហ័ស |
| **HIB** | អង្គការជនពិការអន្តរជាតិ-បែលហ្ស៊ិក |
| **INGOs** | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| **MDG** | គោលដៅអភិវឌ្ឍន៍សហវត្សរ៍ |
| **MoEYS** | ក្រសួងអប់រំ យុវជន និងកីឡា |
| **MRTC** | ក្រុមហ៊ុនការស្រាវជ្រាវទីផ្សារ និងពិគ្រោះយោបល់ជំនួញ |
| **NEP** | អង្គការភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល |
| **NGOs** | អង្គការមិនមែនរដ្ឋាភិបាល |
| **NIS** | វិទ្យាស្ថានជាតិស្ថិតិ |
| **PED** | នាយកដ្ឋានអប់រំថ្នាក់ខេត្ត |

| | |
|---|---|
| **PIT** | ក្រុមការងារអនុវត្តថ្នាក់ខេត្ត |
| **POE** | ការិយាល័យអប់រំថ្នាក់ខេត្ត |
| **PPRPD** | ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ |
| **PWDs** | ជនពិការ |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **SEO** | ការិយាល័យអប់រំពិសេស |
| **TTD** | នាយកដ្ឋានបណ្តុះបណ្តាលគ្រូ |
| **UN** | អង្គការសហប្រជាជាតិ |
| **UNCRPD** | អនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិជនពិការ |
| **UNOHCHR** | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិដើម្បីសិទ្ធិមនុស្សនៅកម្ពុជា |

# ជំពូកទី ១

# សេចក្តីផ្តើម

## ១.១-សាវតានៃការស្ទង់មតិ

ការអប់រំ គឺជាមូលដ្ឋានគ្រឹះសិទ្ធិមនុស្សសម្រាប់មនុស្សគ្រប់រូប។ ការពង្រីកគុណភាពអប់រំមូលដ្ឋាន ត្រូវបាន និងបន្តក្លាយទៅជាកត្តារួមចំណែកយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចលើពិភពលោក។ ក្នុងឆ្នាំ ២000 ប្រធានរដ្ឋ និងរដ្ឋាភិបាលមកពីជុំវិញពិភពលោកបានជួបជុំគ្នា និងព្រមព្រៀងលើចំនុចមួយចំនួននៃគោលដៅអភិវឌ្ឍសហវត្សរ៍ (MDG) ដែលក្នុងនោះការអប់រំជាផ្នែកមួយដ៏សំខាន់។ អាទិភាពយ៉ាងច្បាស់ដែលមានក្នុងគោលដៅសហវត្សរ៍ គឺសម្រេចឱ្យបាននូវការអប់រំបឋមជាសកលត្រឹមឆ្នាំ ២០១៥ (UN, 2000)។ យុទ្ធសាស្ត្រដើម្បីសម្រេចនូវគោលដៅនេះ ត្រូវបានហៅថា *ការអប់រំសំរាប់ទាំងអស់គ្នាឆ្នាំ២០១៥*។ រាជរដ្ឋាភិបាលកម្ពុជា (RGC) ជាប្រទេសហត្ថលេខីនៃគោលដៅអភិវឌ្ឍសហវត្សរ៍ (MDG) និងយុទ្ធសាស្ត្រ *អប់រំសំរាប់ទាំងអស់គ្នា ឆ្នាំ២០១៥*។ ដើម្បីឱ្យស្របតាមបទដ្ឋាននៃការប្តេជ្ញាចិត្ត រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគោលដៅអភិវឌ្ឍសហវត្សរ៍សម្រាប់កម្ពុជា។ គោលដៅទី២ នៃគោលដៅសហវត្សរ៍សម្រាប់កម្ពុជាចែងថា រាជរដ្ឋាភិបាលកម្ពុជា ត្រូវប្តេជ្ញាចិត្ត “សម្រេចឱ្យបាននូវការអប់រំជាមូលដ្ឋានដែលមានរយៈពេល៩ឆ្នាំជាសកលត្រឹមឆ្នាំ ២០១៥”(រដ្ឋាភិបាលកម្ពុជា,ក្រសួងផែនការ ២00៧)។

ដើម្បីសម្រេចគោលដៅអភិវឌ្ឍសហវត្សរ៍ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគោលនយោបាយមួយចំនួនជាការឆ្លើយតប ដែលក្នុងនោះមានផែនការអប់រំសម្រាប់ទាំងអស់គ្នា គោលនយោបាយសាលាកុមារមេត្រី និងគោលនយោបាយអប់រំកុមារពិការ។ ក្រៅពីគោលនយោបាយក្នុងក្របខ័ណ្ឌក្រសួងអប់រំ យុវជន និងកីឡាទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏ជាប្រទេសហត្ថលេខីចំពោះអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (UNCRPD) និងពិធីសារបន្ថែម (OP)។ ជាងនេះទៅទៀត កាលពីខែកក្កដា នៃឆ្នាំ២00៩ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ (PPRPD) ត្រូវបានអនុម័តជាផ្លូវការ។ កិច្ចខិតខំផ្នែកច្បាប់នីមួយៗ ទាមទារឱ្យមានការដាក់បញ្ចូលពេញលេញនូវកុមារពិការ ជាពិសេសការផ្តល់សេវាអប់រំសាធារណៈដល់ពួកគេ។

អង្គការជនពិការកម្ពុជា (អ.ព.ក) យល់ឃើញថា ការអនុវត្តន៍ដ៏មានប្រសិទ្ធិភាពចំពោះគោលនយោបាយទាំងនេះ អាស្រ័យទៅលើថាតើអ្នកអនុវត្ត យល់ដឹងពីគោលបំណងគោលនយោបាយទាំងនោះដល់កម្រិតណា ថាតើពួកគេអាចបកស្រាយអាណត្តិរបស់គោលនយោបាយបានត្រឹមត្រូវ និងច្បាស់លាស់ និងថាតើពួកគេមានធនធាន ការបំពាក់បំប៉ន និងឧបករណ៍គ្រប់គ្រង ដែលចាំបាច់ក្នុងការអនុវត្តគោលនយោបាយផ្សេងៗដែរឬទេ។ ឆ្ពោះទៅដំណើរការនេះ អ.ព.ក បានធ្វើការស្ទង់មតិមួយនេះ ដើម្បីរកឱ្យឃើញពីស្ថានភាពការអប់រំកុមារពិការបច្ចុប្បន្ន។

## ១.២ -គោលបំណងនៃការស្ទង់មតិ

ប្រធានបទនៃការស្ទង់មតិនេះ ត្រូវបានកំណត់តាមរយៈយុទ្ធសាស្ត្របែបចូលរួម ដែលក្នុងនោះគំនិត និង បញ្ហាព្រួយបារម្ភជាច្រើន ត្រូវបានប្រមូលពីប្រធានអង្គការតំណាងជនពិការ (DPOs) និងវេទិការស្ត្រីពិការមកពីទូទាំងប្រទេស។ បុគ្គលម្នាក់ៗ និងអង្គការសំខាន់ៗមកពីផ្នែកពិការភាព និងអប់រំ ត្រូវបានពិគ្រោះយោបល់ជាមួយ ដើម្បីទទួលបានការយល់ដឹងបន្ថែមពីស្ថានភាព និងនិន្នាការបច្ចុប្បន្ន មុនប្រធានបទ និងគោលបំណងនៃការស្ទង់មតិ ត្រូវបានបញ្ចប់។

អ.ព.ក ជាតំណាងសំលេងជនពិការនៅក្នុងប្រទេសកម្ពុជា និង មានបេសកកម្មដែលសំដៅ គាំទ្រ ការពារ បំរើ និងលើកកម្ពស់សិទ្ធិជនពិការ ព្រមទាំងលើកកម្ពស់ផលប្រយោជន៍ជនពិការ ដើម្បីឱ្យ ពួកគេអាចចូលរួមពេញលេញ និងប្រកបដោយសមធមិនៅក្នុងសង្គម។ អ.ព.ក ត្រូវបានបង្កើតនៅក្នុងឆ្នាំ១៩៩៤។ បច្ចុប្បន្ន អ.ព.ក មានសមាជិក ជាង ១០,០០០ (បុរស ស្ត្រី កុមារា និងកុមារីពិការផ្សេងៗគ្នា) ដែលជាសមាជិករបស់ អង្គការតំណាងជនពិការ ចំនួន ៤៨ ក្នុងនោះរួមមានវេទិកាស្ត្រីពិការចំនួន៨ ដែលស្ថិតនៅក្នុងខេត្តចំនួន២៣ នៃប្រទេសកម្ពុជា។ ដើម្បីធ្វើដូច្នេះបាន អ.ព.ក ដើរតួជាអ្នកតស៊ូមតិទាមទាឱ្យមានសិទ្ធិទទួលបានការអប់រំស្មើគ្នា សម្រាប់ក្មេងៗទាំងអស់ ដោយរាប់បញ្ចូលទាំងកុមារពិការផងដែរ។ ហេតុដូច្នេះ គោលបំណងសំខាន់នៅក្នុងការសិក្សានេះ គឺដើម្បីផ្ដល់ការ វិភាគពីស្ថានភាពបច្ចុប្បន្នរបស់កុមារពិការ ទាក់ទងនឹងប្រព័ន្ធអប់រំសាធារណៈ។ ពត៌មានបង្ហាញក្នុងរបាយការណ៍នេះ នឹងជួយជាឯកសារយោង ដែលវឌ្ឍនភាពនៃការអនុវត្តផែនការមេសម្រាប់ កុមារពិការនៅ ប្រទេសកម្ពុជាអាច វាស់វែងបាន។

# ជំពូកទី ២
# ទិដ្ឋភាពរួមស្តីពីពិការភាព និងការអប់រំសម្រាប់កុមារពិការនៅកម្ពុជា

## ២.១. ស្ថានភាពទូទៅរបស់ជនពិការ

### ២.១.១ និយមន័យជនពិការ

និយមន័យពិការភាព ត្រូវបានលើកយកមកជជែកពិភាក្សា ប៉ុន្តែនៅតែមិនមានភាពច្បាស់លាស់ពីតំបន់មួយទៅតំបន់មួយ។ និយមន័យពិការភាពដែលត្រឹមត្រូវតាមផ្លូវច្បាប់ និងមានការទទួលស្គាល់ពីអន្តរជាតិ មានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ។ ទោះជាយ៉ាងនេះក្តី និយមន័យពិការភាពនៅក្នុងច្បាប់ ជាតិស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដែលបានអនុម័តដោយសភាជាតិកាលពីខែថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០០៩ មិនស្របនឹងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការឡើយ។ ភាពខុសគ្នារវាងច្បាប់ជាតិស្តីពី កិច្ចការពារ និង លើកកម្ពស់សិទ្ធិជនពិការ និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ គឺនៅត្រង់អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ ផ្អែកលើគំរូសង្គម/សិទ្ធិជាមូលដ្ឋាន ប៉ុន្តែច្បាប់ជាតិស្តីពីកិច្ចការពារ និងលើកកម្ពស់ សិទ្ធិជនពិការ លើកឡើងតែភាពខ្សោយ ឬ បាត់បង់មុខងារ/ផ្នែក ណាមួយនៃរូបរាងកាយ ដែលបណ្តាល ឱ្យមានពិការភាព។

| ច្បាប់ជាតិស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ (PPRPD) | អនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (UNCRPD) |
|---|---|
| ជនពិការ សំដៅដល់ជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬសតិបញ្ញា បណ្តាលឱ្យមានការរំខានដល់ ជីវភាពរស់នៅ ឬសកម្មភាពនានា ប្រចាំថ្ងៃ ដូចជា ជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកល និងប្រភេទពិការផ្សេងៗទៀតដែលនាំឱ្យមានលក្ខណៈមិនប្រក្រតី។ | ជនពិការ សំដៅលើអ្នកទាំងឡាយដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយសម្បទា ផ្លូវចិត្ត ប្រាជ្ញា ឬ វិញ្ញាណ ដែលនៅពេលជួបប្រទះជាមួយឧបសគ្គនានា អាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធិភាពក្នុងសង្គម ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ។ |

ដោយសារមិនមាននិយមន័យពិការភាពច្បាស់លាស់ ការអនុវត្តគោលនយោបាយ និងផែនការមួយចំនួនដើម្បីលើកកម្ពស់ និងការពារសិទ្ធិជនពិការ ក៏មិនសូវច្បាស់លាស់ផងដែរ។ អង្គការជនពិការកម្ពុជាបាននិងកំពុងលើកទឹកចិត្តរាជរដ្ឋាភិបាលកម្ពុជាក្នុងការកំណត់យកនិយមន័យពិការភាព តាមនិយមន័យដែលមានចែងនៅក្នុងអនុសញ្ញាសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ។

លើសពីនេះទៀត អង្គការជនពិការកម្ពុជា បានធ្វើការតស៊ូមតិផងដែរជាមួយរដ្ឋាភិបាលដើម្បីបង្កើតប្រព័ន្ធចំណាត់ថ្នាក់ពិការភាពថ្មីមួយ ដោយផ្អែកលើវិធីសាស្ត្រផ្អែកលើសិទ្ធិ និងស្របតាមអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការនិងដាក់បញ្ចូលនូវឧបករណ៍កំណត់អត្តសញ្ញាណពិការភាពនៅគ្រប់ការប្រមូលទិន្នន័យប្រជាសាស្ត្រ សំខាន់ៗ។

### ២.១.២ ទិន្នន័យជនពិការ

មិនមានស្ថិតិដែលអាចជឿជាក់បានអំពីប្រេវ៉ាឡង់ពិការភាពនៅកម្ពុជាទេ។ នៅក្នុងឆ្នាំ១៩៩៧ ធនាគារអភិវឌ្ឍន៍អាស៊ី បានធ្វើរបាយការណ៍ថា ៩.៨%នៃជនកម្ពុជាកំពុងរស់នៅជាមួយពិការភាព។ ចំណែករបាយការណ៍របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ឆ្នាំ១៩៩៩ បង្ហាញថា ១៥%នៃប្រជាជនកម្ពុជា គឺជាមនុស្សកំពុងរស់នៅជាមួយពិការភាព (ដកស្រង់ពីអង្គការជនពិការអន្តរជាតិប្រទេសបារាំ ឆ្នាំ២០០៩)។ នៅក្នុងឆ្នាំ ២០០៤ វិទ្យាស្ថានស្ថិតិជាតិបានរកឃើញថា ប្រេវ៉ាឡង់ជនពិការមានចំនួន៤%ក្នុងចំណោមប្រជាជនសរុប (ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចនៅកម្ពុជា២០០៤)។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសម្រេចទទួលយក អត្រានេះជាអត្រាប្រេវ៉ាឡង់ផ្លូវការ។ របាយការណ៍ស្ទង់មតិប្រជាសាស្ត្រកម្ពុជាបញ្ជាក់ថា ២.២% ជាជនពិការ (ការស្ទង់មតិប្រជាសាស្ត្រកម្ពុជា២០០៥)។ ដោយគួរឱ្យភ្ញាក់ផ្អើល របាយការណ៍ចេញផ្សាយថ្មីៗនៃ ជំរឿនទូទៅនូវ ប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ បានបញ្ជាក់ថា អត្រាប្រេវ៉ាឡង់ជនពិការមានតែ១.៤៤% ប៉ុណ្ណោះនៃ ប្រជាជនសរុប (NIS-MoP ២០០៩) ដែលជាតួរលេខមួយដ៏ទាបបំផុត។

អង្គការជនពិការកម្ពុជា ផ្តល់អនុសាសន៍ថា បញ្ជីសំណួរការស្ទង់មតិដ៏ត្រឹមត្រូវមួយ ដែលផ្អែកលើប្រព័ន្ធចំណាត់ថ្នាក់ពិការភាព គួរតែដាក់បញ្ចូលនៅក្នុងបច្ចេកទេសប្រមូលទិន្នន័យជាតិទាំងអស់ ដោយរាប់បញ្ចូលការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជា ជំរឿនចំនួនប្រជាជនកម្ពុជា និងការស្ទង់មតិប្រជាសាស្ត្រកម្ពុជា។

### ២.១.៣ ទិន្នន័យកុមារពិការនៅសាលារៀន

តាមទិន្នន័យរបស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យដឹងថា កុមារទាំងអស់ដែលចុះឈ្មោះចូលរៀននៅសាលារដ្ឋ មានតែ ០.៨%ប៉ុណ្ណោះ (១០៩,៩០០ នាក់) ជាកុមារពិការ។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធប្រមូលទិន្នន័យថ្មីៗនេះ រួមបញ្ចូលប្រភេទពិការភាពចំនួន៦តែប៉ុណ្ណោះ ចំណែក និយមន័យប្រភេទពិការភាពនីមួយៗ មិនបានបញ្ជាក់ជាក់លាក់ទេ។ យោងតាមទិន្នន័យប្រមូលបាន ២.៣២% នៃកុមារកម្ពុជានៅសាលារដ្ឋ មានបញ្ហាលំបាកក្នុងការរៀន ៧៥%មានការលំបាកក្នុងការនិយាយ ៦៣%មានការលំ បាកក្នុងការស្តាប់ ៥៤%មានការលំបាកក្នុងការមើល ៦,២៧៦ នាក់ (២៧%) មានការលំបាកក្នុងការបំលាស់ទី និង ១៩%ទៀត ត្រូវបានកំណត់ថាមានជម្ងឺសុខភាពផ្នែកស្មារតី (ការិយាល័យប្រព័ន្ធពតិមានគ្រប់គ្រងអប់រំ២០០៨)។

យោងតាមការស្ទង់មតិមួយដែលធ្វើឡើងដោយអង្គការសកម្មភាពស្តីពីពិការភាពនិងអភិវឌ្ឍន៍ នៅក្នុងស្រុកឧត្តុង ខេត្តកំពង់ស្ពឺ ជនពិការចំនួន ៣៦% បានចូលរៀននៅសាលាបឋមសិក្សា បើប្រៀបធៀបជាមួយជន មិនការ

មានរហូតដល់ ៥៤% (លោក ហាក់ ២០០៧)។ ម្យ៉ាងទៀត របាយការណ៍នេះ បានបញ្ជាក់ផងដែរថា ជនពិការចំនួន ៤៣% ដែលបានសម្ភាសន៍ ជាអនក្ខរជន ដោយប្រៀបធៀបជាមួយជនមិនពិការមានតិចជាងចំនួន ៩% (យោង របាយការណ៍អង្គការជនពិការអន្តរជាតិប្រទេសបារាំង ២០០៩)។

នៅក្នុងឆ្នាំ២០០៩ CDPO បានធ្វើការស្ទង់មតិមួយទៅលើកុមារពិការចំនួន ២៤០នាក់ នៅក្នុងស្រុកបាធាយ (ខេត្តកំពង់ចាម) នៅស្រុកសំរោងទង និងគងពិសី (ខេត្តកំពង់ស្ពឺ) ស្រុកអង្គរជ័យ និងឈូក (ខេត្ត កំពត) ស្រុកស្វាយទាប និងស្វាយជ្រំ (ខេត្តស្វាយរៀង) ស្រុកសេរីសោភ័ណ្ឌ (ខេត្តបន្ទាយមានជ័យ)។ ក្នុងចំណោម កុមារសុរប ២៤០នាក់ មានកុមារ ១៧៦នាក់ (៧៦%) បានចុះឈ្មោះចូលរៀននៅសាលារៀន។ ប៉ុន្តែ ២៤%នៃកុមារ ពិការត្រូវបានរកឃើញថាមិនបានចូលរៀន។ យោងតាមការស្ទង់មតិសេដ្ឋកិច្ច និងសង្គម ឆ្នាំ២០០៤ ភាគរយនៃកុមារពិការមិនបានចូលរៀនរិតតែខ្ពស់ជាងនេះទៀត គឺមានរហូតដល់ ៣៥% (Knowles, ២០០៥)។

## ២.២. លិខិតគតិយុត្តពាក់ព័ន្ធការអប់រំសម្រាប់កុមារពិការ

### ២.២.១ លិខិតគតិយុត្តអន្តរជាតិ

| |
|---|
| និយមន័យកុមារៈ កុមារគឺជាមនុស្សមានអាយុក្រោម ១៨ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារនីតិភាពត្រូវបានកំណត់ទាបជាងនេះ (អនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិកុមារ មាត្រា១) ។ |

<u>អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ</u>

សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស គូសបញ្ជាក់ថា "មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងភាពសេចក្តីថ្លៃថ្នូរ និងសិទ្ធិ"។ ជនពិការ ក៏ដូចមនុស្សគ្រប់រូបដែរ គឺមានសិទ្ធិដូចគ្នា "ដោយគ្មានការរើសអើងទោះក្នុងលក្ខណៈណាក៏ដោយ"។ សិទ្ធិជនពិការ ត្រូវបានបញ្ជាក់សារជាថ្មីនៅក្នុងគ្រប់សិទ្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។ ដើម្បីលើកកម្ពស់សិទ្ធិជនពិការ អង្គការសហប្រជាជាតិ បានបង្កើត និងអនុម័តអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ ចំណែករាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាទទួលស្គាល់អនុសញ្ញានេះនៅថ្ងៃទី ១ ខែ តុលា ឆ្នាំ២០០៧ និងមានឆន្ទៈធ្វើការផ្តល់សច្ចាប័នក្នុងពេលខាងមុខនេះផងដែរ។ គោលបំណងនៃអនុសញ្ញានេះ គឺដើម្បីលើកស្ទួយ ការពារ និងធានាឱ្យជនពិការទទួលបានដោយពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ និងដើម្បីលើកស្ទួយការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំនើតមករបស់ ជនពិការ។

ចំនុច២ មាត្រា២៤នៃអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ចែងថា *"(ក) ជនពិការមិនត្រូវបានផាត់ចេញពីប្រព័ន្ធអប់រំទូទៅដោយសារតែពិការភាពនោះទេ ហើយកុមារពិការមិនត្រូវបានផាត់ចេញពីការអប់រំដែលខានពុំបាន និងឥតបង់ថ្លៃ នៅកម្រិតបឋម ឬមធ្យមសិក្សា ដោយសារតែពិការភាព។ (ខ) ជនពិការអាចទទួលបាន*

*ការអប់រំរួមគ្នា មានគុណភាព និងមិនបង់ថ្លៃ នៅកម្រិតបឋម និងមធ្យមសិក្សា ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ នៅក្នុងសហគមន៍ដែលគេរស់នៅ*"។

ចំនុច៣នៃមាត្រាដដែរនេះ ចែងថា "*(ក) ជួយសំរួលដល់ការរៀនអក្សរស្ទាប អក្សរជំនួស របៀបនៃការរៀនបែបជំនួយ ព្រមទាំងមធ្យោបាយ និងទម្រង់ផ្សេងៗនៃទំនាក់ទំនង ជំនាញនៃការចល័តនិងតំរង់ទិស ព្រមទាំងជួយសំរួលដល់ការគាំទ្រ និងការណែនាំក្រុមជាដៃគូ។ (ខ) ជួយសំរួលដល់ការរៀនភាសាសញ្ញា និងការលើកស្ទួយអត្តសញ្ញាណផ្នែកភាសារបស់សហគមន៍ជនពិការថ្លង់។ (គ) ធានាថា ការអប់រំសម្រាប់ជនពិការ ជាពិសេសកុមារដែលថ្លង់ ពិការភ្នែក ឬពិការភ្នែកហើយថ្លង់ ត្រូវបានធ្វើឡើងក្នុងទម្រង់និងភាសា និងមធ្យោបាយទំនាក់ទំនងសម្រាប់ជនពិការម្នាក់ៗ ដ៏សមស្របបំផុត ក្នុងបរិយាកាសដែល បង្កើនការអភិវឌ្ឍន៍សង្គម និងសិក្សាធិការជាអតិបរមា*"។

ចំនុច៤ចែងថា "*រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានា ដើម្បីផ្តល់ការងារដល់គ្រូបង្រៀន រួមទាំងគ្រូពិការដែលមានលក្ខណៈសម្បត្តិក្នុងការបង្រៀនភាសាសញ្ញា និង/ឬអក្សរស្ទាប និងដើម្បីបណ្តុះបណ្តាលដល់អ្នកជំនាញ និងបុគ្គលិកដែលធ្វើការនៅគ្រប់កម្រិតសិក្សា*"។

### ២.២.២ លិខិតគតិយុត្តជាតិ និងការអនុវត្តគោលនយោបាយ

<u>ច្បាប់ជាតិស្តីពី កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ</u>

ច្បាប់ស្តីពី កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ត្រូវបានព្រៀងចាប់តាំងពីឆ្នាំ១៩៩៦ ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយសហការជាមួយអង្គការជនពិការកម្ពុជា និងក្រុមប្រឹក្សាសកម្មភាពជនពិការ។ ច្បាប់នេះ ត្រូវបានអនុម័តដោយសភាជាតិកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩។ ច្បាប់នេះ មានគោលដៅការពារ និងលើកកម្ពស់សិទ្ធិជនពិការក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា២៨នៃច្បាប់នេះចែងថា "*រដ្ឋត្រូវបង្កើតគោលនយោបាយ និងយុទ្ធសាស្រ្តជាតិសម្រាប់អប់រំសិស្ស-និស្សិតពិការ ដូចជាការជម្រុញធ្វើសមាហរណកម្មសិស្ស-និស្សិតពិការ ទៅក្នុងថ្នាក់រៀនចម្រុះតាមដែលអាចធ្វើទៅបាន ការបង្កើតថ្នាក់រៀនពិសេស សម្រាប់ឆ្លើយតបនឹងសេចក្តីត្រូវការនៃសិស្ស-និស្សិតពិការ*"។

មាត្រា២៩ចែងថា "*ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំកម្មវិធីសម្រាប់គ្រឹះស្ថានសិក្សានានា ក្នុងការសម្របសម្រួលដល់សិស្ស-និស្សិតពិការនូវផ្នែកមួយចំនួន ដូចជា អគារ បន្ទប់ និងកន្លែងសិក្សា ភាសាសញ្ញា និងអក្សរស្ទាប បច្ចេកទេសអប់រំ និងគរុកោសល្យស្របទៅតាមប្រភេទពិការភាព សម្ភារៈសិក្សា ឬឧបករណ៍ផ្សេងៗសម្រាប់ជំនួយដល់សិស្ស-និស្សិតពិការ សម្ភារៈឧបទេសសម្រាប់គ្រូបង្រៀន ឬសាស្ត្រាចារ្យ និងផ្នែកផ្សេងៗទៀតតាមការជាក់ស្តែងរបស់សិស្ស-និស្សិតពិការម្នាក់ៗ*"។

### ច្បាប់អប់រំឆ្នាំ២០០៧

មាត្រា៣៩នៃច្បាប់អប់រំចែងថា អ្នកសិក្សាពិការមានសិទ្ធិដូចអ្នកសិក្សាមិនពិការដែរ និងមានសិទ្ធិពិសេសដោយឡែកផ្សេងទៀតដូចខាងក្រោម :

- អ្នកសិក្សាពិការទាំងពីរភេទ មានសិទ្ធិសិក្សាជាមួយសិស្ស ឬនិស្សិតទូទៅបាន ប្រសិនបើមានការសម្របសម្រួលសមស្របក្នុងដំណើរការសិក្សា។
- អ្នកសិក្សាពិការ ដែលមិនមានលទ្ធភាពចូលសិក្សាជាមួយសិស្ស ឬនិស្សិតទូទៅបាន មានសិទ្ធិទទួលបានការអប់រំពិសេសនៅសាលារៀនក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួនបាន។

### គោលនយោបាយអប់រំសម្រាប់កុមារពិការ

ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគោលនយោបាយសាលាកុមាមេត្រី ដើម្បីលើកកម្ពស់សិទ្ធិសម្រាប់គ្រប់កុមារទាំងអស់ ដោយរួមបញ្ចូលទាំងកុមារពិការផងដែរ ដើម្បីមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំ។ លើសពីនេះទៀត ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគោលនយោបាយអប់រំកុមារពិការ ដែលបានអនុម័តកាលពីខែមីនា ឆ្នាំ២០០៨ ដើម្បីការពារសិទ្ធិរបស់កុមារពិការក្នុងការទទួលបានសេវាអប់រំប្រកបដោយគុណភាព។

គោលនយោបាយជាតិស្តីពីការអប់រំកុមារពិការមានមានគោលបំណង :

- បង្កើនការយល់ដឹង និងការទទួលស្គាល់ពិការភាពក្នុងសហគមន៍ ស្ថាប័ន និងភាគីពាក់ព័ន្ធ។
- កំណត់អត្តសញ្ញាណ និងផ្តល់បទអន្តរាគមន៍ទាន់ពេលវេលា តាមរយៈសេវាស្តារលទ្ធភាពពលកម្ម ដូចជាការព្យាបាលដោយចលនា សេវាថែទាំសុខភាព ដូចជាការចាក់ថ្នាំបង្ការចំពោះគ្រប់កុមារពិការទាំងអស់តាំងពីកើតរហូតដល់អាយុ៥ឆ្នាំ។
- ផ្តល់ការអប់រំប្រកបដោយគុណភាព បំណិនជីវិត ឬការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារ និងយុវជនពិការប្រកបដោយសមភាព និងប្រសិទ្ធភាព។
- បង្កើនអត្រាប្រមូលកុមារចូលរៀន និងអត្រាគង់វង្ស។

គោលនយោបាយអប់រំកុមារពិការ មាន៦សមាសភាគ :

- សមាសភាគ ទី១: កុមារទាំងអស់បានចូលរៀន
- សមាសភាគ ទី២: ការសិក្សាប្រកបដោយប្រសិទ្ធភាព
- សមាសភាគ ទី៣: សុខភាព សុវត្ថិភាព និងការការពារ
- សមាសភាគ ទី៤: ការឆ្លើយតបទៅនឹងយេនឌ័រ
- សមាសភាគ ទី៥: ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍
- សមាសភាគ ទី៦: ការគាំទ្រកម្មវិធីប្រព័ន្ធអប់រំ

## ផែនការមេសម្រាប់ការអនុវត្តគោលនយោបាយអប់រំកុមារពិការ

ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តផែនការមេមួយដើម្បីអនុវត្តគោលនយោបាយអប់រំកុមារពិការ នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៩។ ផែនការមេនេះ គឺជាផែនការសកម្មភាពច្រើនឆ្នាំ ដែលត្រូវអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា។ ផែនការនេះ ត្រូវបានរៀបចំឡើងជាឧបករណ៍ផ្លូវការមួយ ដើម្បីអនុវត្តគោលនយោបាយអប់រំ កុមារពិការ ដែលបានអនុម័តកាលពីខែមីនា ឆ្នាំ២០០៨។ ផែនការមេដើម្បីអនុវត្តគោលនយោបាយអប់រំកុមារពិការ មានលក្ខណៈស្របគ្នាជាមួយនឹងផែនការមេរបស់សាលាមេត្រីផងដែរ ដែលដើតួនាទីជាផែនការអនុវត្តចម្រុះ ពេញលក្ខណៈសម្រាប់វិស័យអប់រំនៅកម្ពុជា។ ដូចនេះ ផែនការមេត្រូវបានរៀបចំឡើងដើម្បីជួយក្រសួងអប់រំ យុវជន និងកីឡា សម្រេចនូវគោលដៅផែនការយុទ្ធសាស្ត្រអប់រំរបស់ខ្លួន (២០០៦-២០១០) ដែលរៀបចំឡើងដើម្បីសម្រេច ឱ្យបាននូវគោលដៅ និងគោលបំណងយុទ្ធសាស្ត្រជាសាកលនៃការអប់រំសម្រាប់ទាំងអស់គ្នា។ គោលដៅរួមរបស់ គោលនយោបាយអប់រំកុមារពិការ និងផែនការមេ គឺដើម្បីធានាសិទ្ធិកុមារពិការក្នុងការទទួលបានការអប់រំមួយដ៏ ត្រឹមត្រូវ ដោយមានការជួយគាំទ្រ និងដើម្បីឱ្យកុមារទាំងអស់ក្លាយជាប្រជាពលរដ្ឋកម្ពុជាដ៏មានសក្តានុពលបំផុត។

លទ្ធផលរំពឹងទុករបស់គោលនយោបាយអប់រំកុមារពិការ និងផែនការមេ មានដូចជា :

១- បង្កើនការចុះឈ្មោះចូលរៀនកុមារពិការនៅតាមសាលារៀន ដោយលើកកម្ពស់ការយល់ដឹងនៅតាមសហគមន៍ កំណត់អត្តសញ្ញាកុមារពិការទាំងនៅក្នុង និងក្រៅសាលារៀន និងផ្តល់ការគាំទ្រ សមស្រប ចាំបាច់តាមបែបបច្ចេកវិទ្យាដល់កុមារពិការ ដើម្បីឱ្យកុមារទាំងអស់នោះអាចមានលទ្ធភាពចូលសាលារៀន។

២- បង្កើនសមត្ថភាពតាមស្ថាប័ន ដើម្បីឆ្លើយតបទៅនឹងតម្រូវការអប់រំកុមារពិការ តាមរយៈការបណ្តុះបណ្តាលគ្រូបង្រៀន ការបង្កើតមជ្ឈដ្ឋានអប់រំសមរម្យ និងការកែសម្រួលការបង្រៀន និងកម្មវិធីសិក្សាឱ្យបានសមស្រប។

៣- ការលើកកំពស់ការអប់រំប្រកបដោយគុណភាព តាមរយៈការបង្កើតប្រព័ន្ធពិនិត្យតាមដាន និងធានាគុណភាពអប់រំ និងកសាងសមត្ថភាពបុគ្គលិកគ្រប់គ្រងអប់រំដើម្បីអនុវត្តការងារទាំងនោះ។

ផែនការមេ (២០០៩-២០១១) ផ្តល់នូវរយៈពេលមួយសម្រាប់ការអនុវត្តគោលនយោបាយអប់រំកុមារពិការ និងបានដាក់បញ្ចូលម៉ាទ្រិចសម្រាប់ (១) តួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធក្នុងការអប់រំកុមារពិការ (២) សកម្មភាពជាបន្តបន្ទាប់ក្នុងការអនុវត្តការអប់រំកុមារពិការ និងពេលវេលាបណ្តោះអាសន្ន (៣) ការកំណត់ប្រភពមូលនិធិ និងលទ្ធផលសម្រេចបាននាពេលបច្ចុប្បន្ន (៤) វិសាលភាពផែនការមេទាក់ទងទៅនិងអ្នកទទួលផលប្រយោជន៍។

ក្រសួងអប់រំ យុវជន និងកីឡា សូមអំពាវនាវដល់សហគមន៍ និងដៃគូរអភិវឌ្ឍន៍នានាឱ្យប្រើប្រាស់ធនធានផ្ទាល់របស់ខ្លួន (មធ្យោបាយធ្វើដំណើរ សម្ភារៈ និងថវិកា) ដើម្បីលើកកម្ពស់ការអនុវត្តផែនការមេ និង គោល

នយោបាយអប់រំកុមារពិការ និងដើម្បីសម្រេចគោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នានៅមុន និងដំណាច់ ឆ្នាំ ២០១៥។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា បណ្តានាយកដ្ឋានពាក់ព័ន្ធ និងមន្ទីរអប់រំខេត្តទាំងអស់ នឹងរៀបចំផែនការប្រចាំឆ្នាំឱ្យបានសមស្រប ដោយផ្អែកលើផែនការមេចាប់ពីឆ្នាំ២០០៩ ដោយធ្វើកិច្ចសហការជាមួយដៃគូរអភិវឌ្ឍន៍ និងសហគមន៍នានានៅតាមបណ្តាលខេត្តរបស់ខ្លួន ដើម្បីអនុវត្តគោលនយោបាយអប់រំកុមារពិការឱ្យបានជោគជ័យ និង មានប្រសិទ្ធភាពខ្ពស់នៅទូទាំងប្រទេស។

# ជំពូកទី ៣
# វិធីសាស្ត្រក្នុងការស្ទង់មតិ

## ៣.១ ការជ្រើសសំណាក

ការស្ទង់មតិនេះបានពិនិត្យលើបញ្ហាស្ដីពីការអប់រំកុមារពិការនៅក្នុងស្រុកចំនួនប្រាំបីក្នុងខេត្តប្រាំ ដែលអង្គការជនពិការកម្ពុជា មានសមាជិកអង្គការតំណាងជនពិការមានការិយាល័យរបស់ខ្លួន។ ទំហំសំណាករួមមានកុមារពិកា មន្ត្រីអប់រំ ដែលមានពេលវេលាចូលរួមសម្ភាសន៍បាន។ ក្រុមស្ទង់មតិបានសម្ភាសន៍កុមារពិការសរុបចំនួន ២៤០នាក់ ដែលមានប្រភេទពិការភាពផ្សេងៗគ្នា គ្រូបង្រៀនចំនួន ១៦០នាក់ និង នាយកសាលាចំនួន ៨០នាក់។ ការសម្ភាសន៍ជាមួយគ្រូបង្រៀន និងនាយកសាលា ផ្ដោតសំខាន់ទៅលើការប្រមូលព័ត៌មានអំពីការយល់ដឹងនិងចំណេះដឹងថ្មីៗពីគោលនយោបាយអប់រំកុមារពិការ និងវឌ្ឍនភាពចំពោះការអនុវត្ត គោលនយោបាយនេះនៅក្នុងបរិស្ថានសាលារៀនរបស់ខ្លួន។ ចុងក្រោយ មន្ត្រីការិយាល័យអប់រំស្រុកចំនួន ៨នាក់ និងមន្ត្រីមន្ទីរអប់រំ យុវជន និងកីឡាខេត្តចំនួន ៥នាក់ ត្រូវបានជ្រើសរើសដោយចៃដន្យដើម្បីធ្វើបទសម្ភាសន៍ជាបុគ្គល។ គោលបំណងនៃការសម្ភាសន៍ទាំងអស់នេះ គឺដើម្បីប្រមូលព័ត៌មានអំពីកម្រិតចំណេះដឹង និងការយល់ដឹង និងវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ដោយផ្អែកតាមគោលគំនិតយល់ឃើញរបស់មន្ត្រីនៅតាមមន្ទីរថ្នាក់ខេត្ត និងការិយាល័យថ្នាក់ស្រុក។

**តារាង ១: ចំនួន និង ឈ្មោះតំបន់ធ្វើការស្ទង់មតិ**

| អ្នកផ្ដល់ព័ត៌មាន | ស្រុកបាធាយ/កំពង់ចាម | ស្រុកឈូក និង អង្គរជ័យ/កំពត | ស្រុកស្វាយទាប និង ស្វាយជ្រុំ/ស្វាយរៀង | ស្រុកសំរោងទង និង គងពិសី/កំពង់ស្ពឺ | ស្រុកសិរីសោភ័ណ្ឌ/បន្ទាយមានជ័យ |
|---|---|---|---|---|---|
| នាយកសាលា ៨០នាក់ | ១២ | ១៨ | ១៨ | ២៦ | ៦ |
| គ្រូបង្រៀន ១៦០នាក់ | ២៤ | ៣៦ | ៣៦ | ៥២ | ១២ |
| កុមារពិការ ២៤០នាក់ | ៤០ | ៤០ | ៤០ | ៨០ | ៤០ |
| មន្ត្រីមន្ទីរអប់រំ ៥នាក់ | ១ | ១ | ១ | ១ | ១ |
| មន្ត្រីការិយាល័យស្រុក ៨នាក់ | ១ | ២ | ២ | ២ | ១ |

## ៣.២ ការប្រមូលទិន្នន័យ

**ទិន្នន័យទី១:** អ្នកដឹកនាំអង្គការតំណាងជនពិការចំនួន ៦នាក់ ត្រូវបានជ្រើសរើសឱ្យចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី វិធីសាស្ត្រស្រាវជ្រាវ ដែលមានរយៈពេល៤ថ្ងៃ។ វិធីសាស្ត្រនោះ មានបង្ហាញពីទិដ្ឋភាពរួមនៃដំណើរការស្រាវជ្រាវ

ការជ្រើសរើសសំណាក ការបង្កើតបញ្ជីសំណួរ និងការប្រមូលទិន្នន័យនៅមូលដ្ឋាន។ បន្ទាប់ពីរៀនចប់ ឧបករណ៍ប្រមូលទិន្នន័យ (បញ្ជីសំណួរ) ត្រូវបានបង្កើត។ អ្នកសម្ភាសន៍/អ្នកប្រមូលទិន្នន័យ ដែលបានជ្រើសរើសដែលជាប់ទាក់ទងជាមួយសកម្មភាពបានសំដែងតួផងដែរ ដើម្បីអភិវឌ្ឍន៍ជំនាញរបស់ពួកគេក្នុងនាមជាអ្នកប្រមូលទិន្នន័យ និងដើម្បីសាកល្បងរចនាសម្ព័ន្ធឧបករណ៍ប្រមូលទិន្នន័យ។ ក្រោយមកបញ្ជីសំណួរត្រូវបានធ្វើការសាកល្បងជាមុន ជាមួយមនុស្សចំនួន ៤០នាក់ ដើម្បីធានាពី សុពលភាព និងភាពដែលអាចជឿជាក់បាន។ បន្ទាប់ពីការសាកល្បង បញ្ជីសំណួរត្រូវបានកែលម្អឱ្យត្រូវតាម ស្ថានភាពពិតប្រាកដ។

**ទិន្នន័យទី២:** ត្រូវបានប្រមូលតាមរយៈការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណែត អង្គការជាតិ និង អន្តរជាតិ បំរើការងារទាំងក្នុង និងខាងក្រៅវិស័យពិការភាព ព្រមទាំងនៅតាមក្រសួងពាក់ព័ន្ធ ដែលជាស្ថាប័នរបស់រាជរដ្ឋាភិបាល និង គោលនយោបាយផ្សេងៗដែលទាក់ទងនិងការអប់រំកុមារពិការ។

ជំហានបន្ទាប់ ត្រូវទទួលយកលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ លិខតិអនុញ្ញាតនេះបង្ហាញពីគោលបំណងនៃការប្រមូលទិន្នន័យ ហើយវាផ្តល់ការអនុញ្ញាតដល់អ្នកសម្ភាសន៍/ប្រមូលទិន្នន័យរបស់អង្គការជនពិការកម្ពុជា ក្នុងការធ្វើសម្ភាសន៍ជាមួយមន្ត្រីនៅតាមមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក ព្រមទាំងនាយកសាលា គ្រូបង្រៀន និងសិស្សពិការ។ ដំណើរការប្រមូលទិន្នន័យ ចាប់ផ្តើមនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ និងបានបញ្ចប់នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩។ ទិន្នន័យនេះ ត្រូវបានបញ្ចូល និងវិភាគដោយស្ថាប័នស្រាវជ្រាវ (MRTC) និង ត្រូវបានកែសម្រួលចុងក្រោយដោយទីប្រឹក្សាពិការភាពនៃអង្គការជនពិការអន្តរជាតិប្រទេសបែលស៊ិក។

## ៣.៣ បញ្ហាប្រឈម និងដែនកំណត់

ដែនកំណត់សំខាន់នៃរបាយការណ៍នេះ នៅត្រង់ថាទិន្នន័យត្រូវបានប្រមូលពីតំបន់គោលដៅ ដែលនៅក្រៅតំបន់គោលដៅដែលត្រូវអនុវត្តផែនការមេសម្រាប់ការអប់រំកុមារពិការ (២០០៩-២០១១)។ ប៉ុន្តែដោយសារគោលបំណងនៃការសិក្សានេះ គឺដើម្បីវិភាគស្ថានភាពកុមារពិការបច្ចុប្បន្នទាំងនៅក្នុង និងខាងក្រៅប្រព័ន្ធអប់រំរដ្ឋ គេប្រាកដជាជឿថា ទិន្នន័យដែលប្រមូលបាន និងបង្ហាញនៅទីនេះ គឺតំណាងឱ្យស្ថានភាពទូទៅនៃសេវាអប់រំ មុនការអនុវត្តផែនការមេសម្រាប់ការអប់រំកុមារពិការ។

ដែនកំណត់បន្ថែមមួយទៀត នៅត្រង់ថាទិន្នន័យ ត្រូវបានប្រមូលដោយអ្នកស្រាវជ្រាវមិនមែនអាជីព។ បច្ចេកទេសដែលប្រើប្រាស់ រួមមានការជ្រើសរើសសំណាកមិនចៃដន្យ ជាពិសេសនៅពេលជ្រើសរើសកុមារពិការដើម្បីសម្ភាសន៍ និងស្ទង់មតិ។

# ជំពូកទី ៤
# លទ្ធផលនៃការស្ទង់មតិ

ជំពូកនេះ ត្រូវបានបែងចែកជា៩ផ្នែកផ្សេងៗគ្នា។ ផ្នែកនីមួយៗ ត្រួតពិនិត្យលើសកម្មភាពសំខាន់ៗមួយក្នុងចំណោមសកម្មភាពចំនួន១២ ដែលមាននៅក្នុងផែនការមេរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបង្កើតឡើងដើម្បីអនុវត្តគោលនយោបាយអប់រំកុមារពិការ (២០០៩-២០១១)។ យើងបានជ្រើសរើសមិនពិនិត្យមើលសកម្មភាពទី៩ និងសកម្មភាពទី១២ ពីព្រោះវាស្ថិតនៅក្រៅទំហំនៃការសិក្សា។

**សកម្មភាពទី១ : ផ្សព្វផ្សាយគោលនយោបាយអប់រំកុមារពិការ និងផែនការមេដល់ភាគីពាក់ព័ន្ធទាំងអស់ (ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត រាជធានី ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក ខណ្ឌ ក្រុង សាលារៀន គណៈកម្មការទ្រទ្រង់សាលា អង្គការជាតិ និងអន្តរជាតិ និងសហគមន៍ទូទៅ និងក្រសួងពាក់ព័ន្ធ) តាមរយៈកិច្ចប្រជុំ និងយុទ្ធនាការផ្សព្វផ្សាយនានា។**

សកម្មភាពទី១នៃផែនការមេ អំពាវនាវសូមឱ្យមានការផ្សព្វផ្សាយពីគោលនយោបាយអប់រំកុមារពិការ និងផែនការមេដើម្បីអនុវត្តគោលនយោបាយនោះ។ រូប ៤.១ បង្ហាញថា ខណៈពេលដែលមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាភាគច្រើន បានដឹងពីគោលនយោបាយនេះមុនសកម្មភាពផែនការមេត្រូវបានអនុវត្ត ចាំបាច់ត្រូវមានការអនុវត្តសកម្មភាពទាំងនេះ ដើម្បីផ្ដោតការជូនដំណឹងដល់គ្រូបង្រៀន និងនាយកសាលា ដែលទំនងជាបានដឹងពីគោលនយោបាយនោះរួចទៅហើយ។

**រូប ៤.១ : ការដឹងពីគោលនយោបាយអប់រំកុមារពិការ**



ក្នុងចំណោមអ្នកដែលបានជូនដំណឹង អំពីមាតិកានៃគោលនយោបាយអប់រំកុមារពិការ ប្រភពព័ត៌មានចំបងសម្រាប់មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានផ្ដល់ដោយក្រសួងខ្លួនឯង។ សម្រាប់នាយកសាលា ព័ត៌មានបានទទួលពីក្រសួងអប់រំ យុវជន និងកីឡាផង និងពីប្រភពព័ត៌មានផ្សព្វផ្សាយ ដូចជាទូរទស្សន៍/វិទ្យុផង។ សម្រាប់គ្រូបង្រៀន ប្រភពពតិមានចំបងអំពីគោលនយោបាយនេះ បានតាមទូរទស្សន៍/វិទ្យុ (សូមមើលរូប ៤.២)

## រូប ៤.២ : ប្រភពព័ត៌មានអំពីគោលនយោបាយអប់រំកុមារពិការ




ទិន្នន័យបានបង្ហាញផងដែរថា ចំនួនមន្ត្រីក្រសួងអប់រំ និងនាយកសាលាមួយចំនួនធំ បានទទួលវគ្គបណ្ដុះបណ្ដាលផ្លូវការរួចហើយ ពាក់ព័ន្ធនឹងមាតិកាគោលនយោបាយអប់រំកុមារពិការ។ ប្រភពអ្នកផ្ដល់វគ្គបណ្ដុះបណ្ដាលរួមមានក្រសួងអប់រំ និងអង្គការមិនមែនរដ្ឋាភិបាល។ ខណៈដែលមន្ត្រីក្រសួងអប់រំ និងនាយកសាលាមួយចំនួនធំបានចូលរួមរួចរាល់ក្នុងវគ្គបណ្ដុះបណ្ដាលជាច្រើន ចំនួនគ្រូបង្រៀនដែលបានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពីច្បាប់អប់រំកុមារពិការ ស្ថិតក្នុងកម្រិតមួយទាបនៅឡើយ (សូមមើលរូប ៤.៣)។

**រូប ៤.៣ : ចំនួនមន្ត្រីក្រសួងអប់រំ នាយកសាលា និងគ្រូបង្រៀន ដែលបានទទួលវគ្គបណ្តុះបណ្តាលពីមាតិការគោលនយោបាយអប់រំកុមារពិការ**




បច្ចុប្បន្ននេះ នៅមានគម្លាតក្នុងការផ្សព្វផ្សាយឱ្យបានដឹង និងចំណេះដឹងពីគោលនយោបាយអប់រំកុមារពិការ ។ មន្ត្រីក្រសួងអប់រំ និងនាយកសាលា មានចំណេះដឹងពីគោលនយោបាយច្រើនជាងគ្រូបង្រៀន ។ នៅពេលដែលការអនុវត្តផែនការមេចាប់ផ្តើម ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវប្រុងប្រយ័ត្នរៀបចំយុទ្ធសាស្ត្របណ្តុះបណ្តាលផ្សេងៗ ដែលអាចលើកកម្ពស់ការយល់ដឹងក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសគ្រូបង្រៀននៅតាមតំបន់ដាច់ស្រយាល ។

**<u>សកម្មភាពទី២</u> : កំណត់អត្តសញ្ញាណកុមារពិការដល់អាយុចូលរៀន តាមរយៈការធ្វើផែនទីខ្នងផ្ទះ និងយុទ្ធនាការចុះឈ្មោះចូលរៀន ដោយប្រើប្រាស់ឧបករណ៍ជាក់លាក់ និងផ្តល់ការបញ្ជូនទៅរកសេវាសមស្របក្នុងករណីចាំបាច់ ។**

ការកំណត់អត្តសញ្ញាណបានទាន់ពេលវេលាលើកុមារពិការ មានលក្ខណៈពិសេសសម្រាប់ការអភិវឌ្ឍន៍ខ្លួនរបស់ពួកគេ និងសម្រាប់ការដាក់បញ្ចូលទៅក្នុងការអប់រំ ។ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតខិតប័ណ្ណចំនួនប្រាំប្រភេទដែលពិពណ៌នាអំពីការខូចខាតឬបាត់បង់មុខងារ/ផ្នែកណាមួយនៃរាងកាយចំនួនប្រាំប្រភេទ ដូចជា មុខងារក្នុងការស្តាប់ មុខងារក្នុងការមើល មុខងារក្នុងការនិយាយ មុខងារក្នុងការបំលាស់ទី មុខងារក្នុងការចងចាំ ។ ខិតប័ណ្ណទាំងនោះ ក៏មានបញ្ចូលព័ត៌មាន និងសំណួរខ្លះៗដើម្បីជាជំនួយដល់គ្រូបង្រៀន និងនាយកសាលាក្នុងការកំណត់អត្តសញ្ញាណកុមារពិការ និងប្រភេទជំនួយដែលចាំបាច់ ។

ដោយហេតុថា ការបោះពុម្ពខិតប័ណ្ណបានបញ្ចប់នៅចុងឆ្នាំ ២០០៩ នោះវាមិនមែនជាការភ្ញាក់ផ្អើលទេ ដែលថាសកម្មភាពដូចជាការធ្វើផែនទីសហគមន៍ ការធ្វើយុទ្ធនាការចុះឈ្មោះនៅតាមសាលារៀន មិនត្រូវបានអនុវត្តយ៉ាង

ទូលំទូលាយឡើយ។ ក្រសួងអប់រំ យុវជន និងកីឡា ដោយសហការណ៍ជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការ បានដាក់ផែនការរៀបចំសិក្ខាសាលាស្តីអំពីការផ្សព្វផ្សាយខិតប័ណ្ណនៅក្នុងខែមិនា ឆ្នាំ ២០១០។

**<u>សកម្មភាពទី ៣</u> : បង្កើត និងថែរក្សាទិន្នន័យប្រជារាស្ត្រ និងស្ថិតិរបស់កុមារពិការ ដោយប្រើប្រាស់សូចនាករការចុះឈ្មោះចូលរៀន តាមរយៈប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ។**

ការិយាល័យអប់រំពិសេសនៃក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំបានបង្កើត និងបន្តគ្រប់គ្រងប្រព័ន្ធទិន្នន័យស្តីពីកុមារពិការនៅក្នុងសាលានៅទូទាំងប្រទេស (ជួបសម្ភាសន៍ជាមួយលោក ញ៉ាន សារឿន ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១០)។

វានៅតែមិនច្បាស់អំពីរបៀបនៃការប្រមូល និង បញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធពតិមានគ្រប់គ្រងអប់រំ (EMIS) ដែលអាចកើតមានជាក់ស្តែង។ នៅពេលប្រមូលទិន្នន័យនៃការស្ទង់មតិ "ការពិនិត្យឡើងវិញលើប្រព័ន្ធចំណាត់ថ្នាក់ពិការភាព" មិនទាន់បានបង្កើតឡើងទេ។ អ្វីដែលសំខាន់ ការពិនិត្យឡើងវិញលើប្រព័ន្ធចំណាត់ថ្នាក់ពិការភាពបច្ចុប្បន្ន ត្រូវបានកំណត់ជាអាណត្តិយ៉ាងជាក់លាក់នៅក្នុងផែនការមេសម្រាប់អនុវត្តន៍គោលនយោបាយ ស្តីពីការអប់រំកុមារពិការ។

បទសម្ភាសន៍ដែលធ្វើឡើងជាមួយនាយកសាលាដែលបានជ្រើសរើស បង្ហាញថា សម្រង់ពតិមានមិនផ្លូវការរបស់គ្រូ ជាវិធីសាស្ត្រសាមញ្ញដែលត្រូវបានប្រើដើម្បីកំណត់រកកុមារពិការនៅក្នុងប្រព័ន្ធសាលារដ្ឋ។

**រូប ៤.៤ ប្រភពពតិមានអំពីចំនួនកុមារពិការនៅក្នុងសហគមន៍មូលដ្ឋាន - ចម្លើយនាយកសាលា**




វាចាំបាច់សម្រាប់គ្រូបង្រៀនដើម្បីពិនិត្យ និងកំណត់អត្តសញ្ញាណកុមារពិការនៅក្នុងថ្នាក់រៀន ហើយវាក៏សំខាន់ផងដែរ ដែលទិន្នន័យ EMIS ត្រូវបានប្រមូល និងវិភាគ ដើម្បីផ្តល់ព័ត៌មានដ៏មានតម្លៃ ទាក់ទងទៅនឹងតម្រូវការអប់រំរបស់កុមារពិការ នៅក្នុងប្រព័ន្ធសាលារដ្ឋ។ ទោះយ៉ាងណាក៏ដោយ បើគ្មានឧបករណ៍ពិនិត្យល្អប្រសើរទេ ការពិនិត្យមិនផ្លូវការដែលគេកំពុងអនុវត្តនាពេលបច្ចុប្បន្នអាចនាំទៅរកការរើសអើង។

ជាសំខាន់នោះ គំរោងមួយដែលផ្តល់មូលនិធិដោយគណៈកម្មាធិការសហប្រជាជាតិទទួលបន្ទុកសេដ្ឋកិច្ចសង្គម ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (UNESCAP) ក្នុងភាពជាដៃគូជាមួយវិទ្យាស្ថានជាតិស្ថិតិ បានធ្វើការស្រាវជ្រាវស្ទង់មតិ ទៅលើគ្រួសារចំនួន ១,០០០គ្រួសារ ដើម្បីសាកល្បងប្រព័ន្ធចំណាត់ថ្នាក់ពិការថ្មីនៅកម្ពុជា។ បច្ចុប្បន្ន ក្រុមការងារមួយ ត្រូវបានបង្កើតឡើង ដើម្បីពិនិត្យមើលលទ្ធផលនៃការស្ទង់មតិសាកល្បងនេះ និងកែលំអរឧបករណ៍ស្ទង់មតិអោយ សមស្របទៅនឹងបរិបទនៅកម្ពុជា។ ទោះជាយ៉ាងនេះក្តី វានៅមិនទាន់ប្រាកដទេថា តើនៅពេលណាប្រព័ន្ធចំណាត់ថ្នាក់ ថ្មី នឹងត្រូវបង្កើតឡើងពេញលេញ និងដាក់បញ្ចូលទៅក្នុងការធ្វើជំរឿនប្រជារាស្ត្រកម្ពុជា ការស្រាវជ្រាវសេដ្ឋកិច្ច-សង្គមនៅកម្ពុជា ឬទិន្នន័យនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ឬយ៉ាងណា នោះទេ។

កង្វះការទទួលយកប្រព័ន្ធចំណាត់ថ្នាក់ជាតិសម្រាប់ជនពិការ នឹងនាំអោយមានផលប៉ះពាល់ជាអវិជ្ជមានគ្រប់ រូបភាពដល់ការអនុវត្តសកម្មភាពសំខាន់ទីបីនៃផែនការមេ។ ក្រសួងអប់រំ យុវជន និងកីឡា គួរតែចូលរួមនៅក្នុងក្រុម ការងារចាត់ចំណាត់ថ្នាក់ពិការភាព ដែលសម្របសម្រួលដោយក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រោមការ ដឹកនាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារ ដើម្បីជំរុញដល់ការបង្កើត និងអនុវត្តន៍ពេញលេញនូវ ប្រព័ន្ធចាត់ចំណាត់ថ្នាក់ជនពិការជាតិថ្មី ដោយឈរលើនិយមន័យពិការភាពដែលចែងនៅក្នុងអនុសញ្ញាអន្តរជាតិ។

**<u>សកម្មភាពទី ៤</u> : អភិវឌ្ឍន៏កម្មវិធី បណ្តុះបណ្តាលដើម្បីកំណត់អត្តសញ្ញាណ និងបង្រៀនកុមារពិការនៅ មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាក្នុងបែបផែនផ្សេងគ្នានៃមជ្ឈដ្ឋានអប់រំ។**

ក្នុងកំឡុងពេលនៃការប្រមូលទិន្នន័យ សៀវភៅបណ្តុះបណ្តាលស្តីពីការអប់រំបញ្ចូលគ្នាចំនួនពី ត្រូវបានបង្កើត ឡើង ដោយការិយាល័យអប់រំពិសេស (SEO) និងនាយកដ្ឋានបណ្តុះបណ្តាលគ្រូ (TTD) "ជួបសំភាសន៍ជាមួយបណ្ឌិត ម៉ាយ៉ា កល្យាណពូរ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១០"។ ចាប់ពី ខែមករា ដល់ ខែធ្នូ ឆ្នាំ ២០០៩ ចំនួនសរុប នៃអ្នកដែលទទួលបានការបណ្តុះបណ្តាល គឺ ១,៦១៦ នាក់ (ស្រី ២៦៥) ដែលមានសមាសភាពជា មន្ត្រីថ្នាក់ជាតិ ខេត្ត និង ស្រុក និងគ្រូបង្រៀនថ្នាក់ទី១។ ចំនួនសៀវភៅបណ្តុះបណ្តាល ដែលបានបោះពុម្ពគឺ ៧,៦០០ ក្បាល។ វាមិនមែន ជាការភ្ញាក់ផ្អើលទេ ដែលលទ្ធផលបានបង្ហាញថា មានភាគរយមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា តិចប៉ុណ្ណោះ ដែលបានទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រអប់រំកុមារពិការ។ ការស្ទង់មតិមិនបានសួរ ថាតើពួកគេទទួលបានការ បណ្តុះបណ្តាលដោយវិធីណា ឬ ពីប្រភពណានោះឡើយ (មើលរូប ៤.៥ និង ៤.៦)។

លើសពីនេះទៅទៀត នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការបង្កើតទម្រង់ជាមូលដ្ឋាន មួយដើម្បីបង្កើតកម្មវិធីសិក្សា។ សិក្ខាសាលានេះបានកំណត់នូវតំរូវការវគ្គបណ្តុះបណ្តាលចំនួន ៤ សំខាន់ៗ រួមមាន ការបណ្តុះបណ្តាលគ្រូជាលក្ខណៈស្តង់ដាខ្លីមួយសម្រាប់គ្រូស្តីពីការអប់រំបញ្ចូលគ្នា និង មេរៀនស្តង់ដាចំនួន ៣ ទៀត ដែលបានអនុញ្ញាតដោយរាជរដ្ឋាភិបាលៈ ១) ការអប់រំមនុស្សថ្លង់សម្រាប់បណ្តុះបណ្តាលគ្រូប ដើម្បីបង្រៀនសិស្ស ពិបាកខាងការស្តាប់ ២) ការអប់រំអក្សរស្ទាបសម្រាប់បណ្តុះបណ្តាលគ្រូ បង្រៀនសិស្សពិបាកខាងការមើល និង ៣) ការអប់រំពិសេសសម្រាប់គ្រូបង្រៀនសិស្សខ្សោយបញ្ញា។ ដោយផ្អែកទៅលើមាតិកានៃសិក្ខាសាលា ក្រុមការងារអ្នក

បណ្តុះបណ្តាលថ្នាក់ជាតិត្រូវបានបង្កើតឡើង ដែលមានសមាសភាពមកពីនាយកដ្ឋានបណ្តុះបណ្តាលគ្រូ នាយកដ្ឋានអប់រំផែនការ និង នាយកដ្ឋាន អភិវឌ្ឍន៍កម្មវិធីសិក្សា។ បច្ចុប្បន្នក្រុមការងារនេះ កំពុងដំណើរការបង្កើតវគ្គបណ្តុះបណ្តាលស្តង់ដាស្តីពីការអប់រំបញ្ចូលគ្នា។ ក្រុមការងារដដែលនេះនិងចូលរួមបង្កើតនូវវគ្គបណ្តុះបណ្តាលបី បន្ថែមទៀតនៅក្នុងអនុក្រុម និងសហការជាមួយ និងអង្គការដែលពាក់ព័ន្ធផ្សេងទៀត។

**រូប ៤.៥ : ភាគរយមន្ត្រីក្រសួងអប់រំ ដែលបានទទួលការបណ្តុះបណ្តាលពីរបៀបបង្រៀនកុមារពិការ**




**រូប ៤.៦ : ភាគរយមន្ត្រីក្រសួងអប់រំ ដែលបានទទួលសម្ភារៈសម្រាប់បង្រៀនកុមារពិការ**




<u>សកម្មភាពទី ៥</u> : បណ្តុះបណ្តាលគ្រូមត្តេយ្យសហគមន៍ និងគ្រូមត្តេយ្យសិក្សារដ្ឋ ដើម្បីកំណត់អត្តសញ្ញាណ និង បង្រៀនកុមារពិកាដែលគ្រប់អាយុចូលសាលាមត្តេយ្យសិក្សារដ្ឋ

<u>សកម្មភាពទី ៦</u> : បណ្តុះបណ្តាលគ្រូ និងនាយកសាលាបឋមសិក្សា ដើម្បីកំណត់អត្តសញ្ញាណ និងបង្រៀនកុមារពិការគ្រប់អាយុចូលសាលាបថមសិក្សាក្នុងក្របខណ្ឌសាលាកុមារមេត្រីដោយប្រើប្រាស់វិធីសាស្ត្រប្រសិទ្ធភាពនៃការបង្រៀន និងរៀនសកម្មភាពមិត្តជួយមិត្ត។

**រូប ៤.៧ ៖ ភាគរយមន្ត្រីក្រសួងអប់រំ ដែលបានទទួលការបណ្តុះបណ្តាលពីរបៀបកំណត់អត្តសញ្ញាណកុមារពិការ**




